## ខ្លឹមសារសង្ខេប សាលដីកាតុលាការកំពូលបង់ក្លាដែស ( Dr. Mohiuddin Farooque v Bangladesh, 1996 )

### ពាក្យគន្លឹះ៖ អ្នកមានសិទ្ធិប្តឹង (legal standing) ផលប្រយោជន៍សាធារណៈ សិទ្ធិរស់រានមានជីវិតនិងបរិស្ថានស្អាត

### ១. នីតិវិធី

ម្ចាស់បណ្តឹង ជាអគ្គលេខាធិការនៃសមាគមមេធាវីបរិស្ថាននៃប្រទេសបង់ក្លាដេស (BELA) បានប្តឹងប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះតុលាការជាន់ខ្ពស់ ដែលបានបដិសេធញ្ញត្តិ ដាក់ក្នុងនាមជាសមាជិកនៅក្នុងស្រុក Tangail, ដែលជីវិត ទ្រព្យសម្បត្តិ ជីវភាពរស់នៅ ការងារ និងសន្តិសុខបរិស្ថាន ត្រូវបានបំពានធ្ងន់ធ្ងរ ដោយការអនុវត្តផែនការគ្រប់គ្រងទឹកជំនន់នៃគម្រោងសាកល្បង FAP-20។ ញត្តិ ត្រូវបានតុលាការជាន់ខ្ពស់បដិសេធដោយ ផ្អែកលើមូលដ្ឋានថា BELA មិនមែនជាបុគ្គលទទួលរងគ្រោះ អនុលោមតាមមាត្រា១០២នៃរដ្ឋធម្មនុញ្ញរបស់បង់ក្លាដេសនោះឡើយ។ មាត្រា៣១ និងមាត្រា៣២នៃរដ្ឋធម្មនុញ្ញ ការពារសិទ្ធិរស់រានមានជីវិតដែលជាសិទ្ធិមូលដ្ឋាន។ ក៏ប៉ុន្តែរដ្ឋធម្មនុញ្ញនេះ ពុំមានចែងអំពីសិទ្ធទទួលបានបរិស្ថានមានសុវត្ថិភាពនោះទេ។ សំណួរនៅចំពោះមុខតុលាការ គឺថាតើសិទ្ធិជាមូលដ្ឋាននេះ រួមមានការការពារ និងការថែរក្សាបរិស្ថាន តុល្យភាពអេកូឡូស៊ីនិងបរិស្ថាន ដែលគ្មានការបំពុល ចាំបាច់ក្នុងការប្រាស្រ័យសិទ្ធិរស់រានមានជីវិត ដែរឬទេ?

### ២. ក្របខណ្ឌច្បាប់ (Legal Framework)

មាត្រា៣១ មាត្រា៣២ និងមាត្រា១០២ រដ្ឋធម្មនុញ្ញនៃប្រទេសបង់ក្លាដេស

## ៣. សម្រេច

អង្គភាពឧទ្ធរណ៍នៃតុលាការកំពូលរបស់ប្រទេសបង់ក្លាដេស បានអនុញ្ញាតនូវបណ្តឹងឧទ្ធរណ៍ ដោយបានផ្តល់សិទ្ធិឲ្យអ្នកប្តឹងនូវ Locus Standi ប្តឹងទៅកាន់តុលាការជាន់ខ្ពស់ យោងតាមមាត្រា១០២ នៃរដ្ឋធម្មនុញ្ញ ដោយអះអាងថា "បុគ្គលណាដែលទទួលរងផលប៉ះពាល់" ដូចដែលមានចែងនៅក្នុង មាត្រា១០២នៃរដ្ឋធម្មនុញ្ញ គឺមិនត្រូវបានកំណត់ចំពោះលើបុគ្គលដែលទទួលរងផលប៉ះពាល់តែប៉ុណ្ណោះ ទេ ក៏ប៉ុន្តែត្រូវពង្រីកវិសាលភាពដល់បុគ្គលគ្រប់រូបជាទូទៅ ដូចជាក្រុមមនុស្ស (collective and consolidated personality)។ តុលាការបានពិចារណានូវអំណះអំណាងរបស់ BELA នៅក្នុងញត្តិ និង សេចក្តីសន្និដ្ឋានថា BELA គួរតែត្រូវទទួលបាន Locus Standi ដើម្បីដាក់ញត្តិ ដែលក្នុងរឿងនេះ BELA ជាជនរងគ្រោះ ក្នុងខ្លឹមសារនៃមាត្រា១០២នៃរដ្ឋធម្មនុញ្ញ ដោយសារ " ជាមូលហេតុពិត គាំទ្រទាំងសិទ្ធិ ចម្បងនិងដំណោះស្រាយតាមរដ្ឋធម្មនុញ្ញ និងជាមូលហេតុនៃបណ្តឹងរបស់មនុស្សច្រើនគ្មានកំណត់ ទាក់ទងប្រយោជន៍សាធារណៈ។

ខ្លឹមសារនៃ 'បុគ្គលដែលទទួលរងការប៉ះពាល់" ដែលប្រហាក់ប្រហែលទៅនឹងអ្វី ក្នុងន័យ ទូលាយ ជាផលប្រយោជន៍គ្រប់គ្រាន់ "**Sufficient Interest**" ។ បុគ្គលណាមួយក្រៅពីបុគ្គលអន្តរាគមន៍ ជាផ្លូវការ ដែលគ្មានផលប្រយោជន៍ក្នុងបណ្តឹង លើសពីផលប្រយោជន៍របស់ប្រជាពលរដ្ឋទូទៅនៃប្រទេ ស មានផលប្រយោជន៍គ្រប់គ្រាន់ក្នុងកម្មវត្ថុនៃបណ្តឹង គឺជាជនរងគ្រោះ និងអាចដាក់ញត្តិ ដើម្បីតុលា ការដោះស្រាយ នូវផលប៉ះពាល់ជាសាធារណៈ កើតមានពីការរំលោភបំពានកាតព្វកិច្ចសាធារណៈ ឬការ បំពាននៃបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញឬច្បាប់ និងស្វែងរកការអនុវត្តនូវករណីកិច្ចសាធារណៈ ព្រមទាំងការ

គោរពច្បាប់និងរដ្ឋធម្មនុញ្ញ។ ស្តង់ដាររវាស់វែងនៃផលប្រយោជន៍គ្រប់គ្រាន់ ផ្អែកជាចម្បងទៅលើទំនាក់ទំនងរវាងបញ្ហាដាក់មកតុលាការ និងបុគ្គលដែលជាអ្នកដាក់បណ្តឹង”(Hon. Mr. Justice A.T.M AFZAL, Chief Justice) ។

“បើទោះបីជាយើងមិនមានបទប្បញ្ញត្តិណាមួយដូចមាត្រា៤៨កនៃរដ្ឋធម្មនុញ្ញប្រទេសឥណ្ឌា សម្រាប់ការការពារបរិស្ថានក៏ដោយ មាត្រា៣១និងមាត្រា៣២ រដ្ឋធម្មនុញ្ញរបស់យើង ការពារសិទ្ធិរស់រានមានជីវិត ដែលជាសិទ្ធិចម្បង។ វាមានវិសាលភាពក្តោបដល់ ការការពារ និងអភិរក្សបរិស្ថាន តុល្យភាពអេកូឡូស៊ីដោយគ្មានការបំពុលខ្យល់និងទឹក អនាម័យ ដែលគ្មានវា ជីវិតនឹងពិបាករស់រានបាន។ សកម្មភាព ឬការខកខានណាមួយ ដែលផ្ទុយ នឹងជាការបំពានសិទ្ធិរស់រានមានជីវិត។ (Hon. Justice B.B Roy Choudhury) ។

**Cases Cited ;** Blackburn v. Attorney General [1971] 1 WRL 1037; Durayapph v. Fernando [1967] 2 AC 337; Giasuddin Bhuiyan v. Bangladesh 1 (1981) BCR (AD) 81; IRC v. National Federation of Self Employment and Small Business Ltd. [1981] 2 All ER 93 ; Mian Fezal Din v. The Lahore Improvement Trust 21 DLR (SC) 225 ; Muntizma Committee v. Director Katchi Ahadies, Sindh PLD 1992 (Karachi); RS Secretary of State for the Environment, ex parte Rose Theatre Trust Co. (Qbd) [1990] 1 All ER 754; Shehla Zia v. WAPDA PLD 1994 (SC) 693; Sierra Club v. Morton 401 US 907 (1971) (No. 70-34)

## កំណត់សំគាល់

នៅក្នុងនីតិវិធីតុលាការ ច្បាប់បានកំណត់អំពីបុគ្គលដែលមានសិទ្ធិប្តឹង។ ជាទូទៅ រូបវន្តបុគ្គលដែលជាជនរងគ្រោះ មានសិទ្ធិប្តឹង។ ច្បាប់មិនបានចែង ឬចែងមិនច្បាស់ អាចនាំឲ្យមានការបដិសេធនូវពាក្យបណ្តឹង ដោយតុលាការ។ ក្នុងរឿងនេះ ក្រុមមេធាវីជាអ្នកប្តឹង ពាក់ព័ន្ធសិទ្ធិបរិស្ថានមានសុវត្ថិភាព។ តុលាការជាន់ទាបបដិសេធ ដោយអះអាងថាក្រុមមេធាវី មិនមែនជាជនរងគ្រោះ ឬរងផលប៉ះពាល់។ តុលាការកំពូលបានសម្រេចបកយ៉ាងទូលាយនូវបទប្បញ្ញត្តិច្បាប់រដ្ឋធម្មនុញ្ញពាក់ព័ន្ធ ដោយអនុលោមតាមទ្រឹស្តី មាន sufficient interest បន្ថែមពីលើនេះ ដាក់សិទ្ធិបរិស្ថានមានសុវត្ថិភាព (ទោះបីមិនមានចែងក្តី) ក្នុងសិទ្ធិរស់រានមានជីវិត។ នេះដោយផ្អែកលើផលប្រយោជន៍សាធារណៈ។ សាលដីកានេះគួរត្រូវបានសាទរ និងយោងដល់ ដោយសារវាគាំទ្រការការពារបរិស្ថាន។

សំណុំរឿងនេះពាក់ព័ន្ធនឹងសិទ្ធិប្តឹងទៅតុលាការ (Right to Access to Justice) ដែលជាប្រធានបទមួយ មានសារៈប្រយោជន៍ តែមិនទាន់មានការសិក្សាផុសផលនៅកម្ពុជា។ អត្ថបទជា ភាសាអង់គ្លេស អាចរកបាន (Environmental Case Summary, p.105)។